**អង្គរបុរី**
**សម្លេងខ្មែរនៅបរទេស**

# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ ក្រោមប្រធានបទ ធម្មនុញ្ញនៃសិទ្ធិមនុស្សអំពីសិទ្ធិពលរដ្ឋនិងឆន្ទៈប្រជាពលរដ្ឋជាគ្រឹះនៃអំណាចប្រៀបធៀបមកព្រះពុទ្ធសាសនា ។

website: www.hoksavann.org

ថ្ងៃទី២០ វិច្ឆិកា ២០០៧



មាត្រា២១ប្រការ១នៃធម្មនុញ្ញសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិបានចែងថា បុគ្គលគ្រប់រូបមានសិទ្ធិចូលរួមកាន់កាប់កិច្ចការគ្រប់គ្រងប្រទេសរបស់ខ្លួនដោយផ្ទាល់ខ្លួន ឬតាមរយៈអ្នកតំណាងទាំងឡាយដោយសេរី ។ មាត្រានៃច្បាប់នេះមានន័យថា ពលរដ្ឋម្នាក់ៗនៃប្រទេសមួយមានសិទ្ធិគិតគូរអំពីវាសនាប្រទេសរបស់ខ្លួន ហើយមានសិទ្ធិចូលរួមគ្រប់កិច្ចការរបស់រដ្ឋដោយផ្ទាល់ខ្លួន ឬតាមរយៈអ្នកតំណាង ។ បានសេចក្តីថា ពលរដ្ឋមានសិទ្ធិប្រឡងប្រជែងចូលកាន់កិច្ចការរដ្ឋ ឬឈរឈ្មោះឲ្យគេជ្រើសរើសដោយសេរី និងមានសិទ្ធិជ្រើសរើសតំណាងរបស់ខ្លួនឲ្យចូលរួមក្នុងកិច្ចការរដ្ឋ ។

មាត្រា២១ប្រការ២ចែងថា បុគ្គលគ្រប់រូបមានសិទ្ធិចូលកាន់មុខងារក្នុងតំណែងសាធារណៈនៃប្រទេសរបស់ខ្លួនដោយស្មើមុខ ។ គឺពលរដ្ឋមួយរូបៗមានសិទ្ធិស្មើគ្នាក្នុងការចូលកាន់តំណែងក្នុងរដ្ឋទៅតាមសមត្ថភាព និងទៅតាមការបោះឆ្នោតដោយគ្មានលក្ខខណ្ឌដោយទ្រព្យសម្បត្តិ ដោយពូជអម្បូរណ៍កូនអ្នកធំកូនអ្នកតូចឡើយ ។

មាត្រាច្បាប់នេះ បើប្រៀបធៀបមកពុទ្ធសាសនាវិញ ព្រះពុទ្ធសំដែងថា មនុស្សគ្រប់រូបកើតមកពីធាតុបួនដូចគ្នា តែដែលធ្វើឲ្យមនុស្សប្លែកគ្នានោះ គឺដោយសារអំពើ ឬកម្ម ឬការងារដែលគេបានធ្វើ ។ បុគ្គលមានឋានៈបែបណាក៏ដោយ បើគេប្រព្រឹត្តអាក្រក់ដោយកាយវាចាចិត្ត ចាត់ទុកជាបុគ្គលថោកទាប ។ បុគ្គលដែលប្រព្រឹត្តល្អ ដោយកាយវាចា

ចិត្ត ចាត់ទុកជាបុគ្គលខ្ពង់ខ្ពស់ថ្លៃថ្នូរ ។ ដូច្នេះទំនាបនិងកំពស់របស់មនុស្ស ត្រូវស្ថិតនៅលើអំពើរបស់គេ ពុំមែនស្ថិតនៅលើទ្រព្យសម្បត្តិយសសក្តិជាតិត្រកូលឡើយ ។

មាត្រា២១ប្រការ៣នៃធម្មនុញ្ញសិទ្ធិមនុស្សចែងថា ឆន្ទៈប្រជាជនជាគ្រឹះនៃអំណាចសាធារណៈ ។ ឆន្ទៈនេះត្រូវបញ្ចេញតាមរយៈការបោះឆ្នោតជាសាកល ដោយត្រឹមត្រូវនិងសម្ងាត់ ឬតាមវិធីដូចគ្នា ដែលមានការធានារ៉ាប់រងសេរីភាពដល់ការបោះឆ្នោត ។ មាត្រានៃច្បាប់នេះបញ្ជាក់ថា អំណាចគ្រប់យ៉ាងកើតចេញមកពីប្រជាជនជាពលរដ្ឋ ប្រជាជនជាម្ចាស់នៃអំណាច អំណាចកើតចេញមកពីឆន្ទៈរបស់ប្រជាជន តាមរយៈការបោះឆ្នោតដោយត្រឹមត្រូវ ដោយគ្មានការបន្លំ ។ ពាក្យថាជាសាកលបានន័យថា ជាទូទៅ ។ ពាក្យថាសម្ងាត់បានន័យថា ពុំឲ្យជនណាម្នាក់ដឹងថា បោះឆ្នោតឲ្យអ្នកណា ។ មាត្រាដែលថាតាមវិធីដូចគ្នាដែលមានការធានារ៉ាប់រងសេរីភាពដល់ការបោះឆ្នោត បានន័យថា ឲ្យមានអ្នកធានាការពារកុំឲ្យជនណា ឬក្រុមណាគំរាមកំហែងបង្ខិតបង្ខំសូកប៉ាន់ឲ្យបោះឆ្នោតឲ្យគណបក្សណា ដែលបុំស្របតាមឆន្ទៈរបស់ប្រជាពលរដ្ឋ ។ នេះជាអត្ថន័យនៃរបបប្រជាធិបតេយ្យ ដែលមានប្រជាពលរដ្ឋជាធំជាអធិបតីជាម្ចាស់អំណាច ។ ប្រៀបមកពុទ្ធសាសនា ក្នុងពេលដែលព្រះសង្ឃកើតឡើងមានចំនួនច្រើនហើយ ព្រះសម្ពុទ្ធបានអនុញ្ញាតឲ្យព្រះសង្ឃសំរេចកិច្ចការគ្រប់យ៉ាងក្នុងព្រះពុទ្ធសាសនា ដោយការប្រជុំសំរេចពីប្រជុំសង្ឃតាមទីកន្លែងនីមួយៗ ។ សមាជិកព្រះសង្ឃដែលមកប្រជុំមានចំនួនច្រើនតិចយោលទៅតាមទំហំការងារដែលសំខាន់ល្មមនិងសំខាន់ខ្លាំង ដែលហៅថាសង្ឃកម្ម ។ ការខ្លះដែលជាកាតព្វកិច្ចរបស់ព្រះសង្ឃ ដែលត្រូវតែធ្វើដូចឧបោសថកម្ម គ្រាន់តែសូត្រប្រកាសប្រាប់ឲ្យសង្ឃដឹងហៅថាញត្តិទុកជាបានការ គ្មានការពិភាក្សាគ្នាទេ ។ ការខ្លះសំខាន់ល្មមដូចជាកឋិនកម្ម ត្រូវប្រកាសប្រាប់សង្ឃហៅថាញត្តិ ហើយត្រូវសួរឲ្យសំរេចតែម្តងហៅថា ញត្តិទុតិយកម្មវាចា ដើម្បីឲ្យស្រុះស្រួលគ្នាប្រគល់សំពត់កឋិនឲ្យអង្គណាមួយក្រាលគ្រងកឋិន ។ បើការងារដែលសំខាន់ខ្លាំងដូចជា ឧបសម្បទាកម្ម គឺជាការសំរេចឲ្យបួសជាភិក្ខុ ត្រូវប្រកាសម្តងដែលហៅថាញត្តិ ហើយសួរយោបល់ព្រះសង្ឃរហូតដល់៣ដង តើសំរេចឲ្យបួសឬមិនឲ្យបួស ហៅថាចតុត្ថកម្មវាចា ព្រោះថាការអនុញ្ញាតឲ្យមនុស្សម្នាក់បួស ត្រូវពិនិត្យពិច័យពិចារណាឲ្យបានម៉ត់ចត់ កុំឲ្យខូចតម្លៃព្រះពុទ្ធសាសនាដោយសារតែឲ្យមនុស្សមិនល្អបួស ។ ការចាត់ភិក្ខុសង្ឃអង្គណាមួយ ឲ្យបំពេញកិច្ចការរបស់សង្ឃ ដូចជាការចាត់ឲ្យទៅឲ្យឱវាទដល់ភិក្ខុនី ចាត់ឲ្យទទួលភារៈបំរើសង្ឃជាដើមតែងតែចាត់ទៅតាមសមត្ថភាពនិងគុណធម៌របស់សង្ឃនោះ ។

ក្រឡេកមើលរបបកុម្មុយនិស្តជាពិសេសកុម្មុយនិស្តខ្មែរក្រហម ប្រជាធិបតេយ្យគ្មានទេ ការបោះឆ្នោតដោយសេរីនិងយុត្តិធម៌ក៏គ្មានសោះឡើយ ព្រោះរបបនេះមានគណបក្សតែមួយ គេឲ្យប្រជាពលរដ្ឋបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រតំណាងប្រជាជន គឺ

ជាបក្ខជនដែលមជ្ឈិមបក្សតែងតាំងរួចហើយ ។ ការបោះឆ្នោតនេះគ្មានន័យអ្វីឡើយ គ្រាន់តែជាសកម្មភាពខាងក្រៅ បន្លំភ្នែកអន្តរជាតិឲ្យមើលឃើញថា របបនេះគោរពសិទ្ធិពលរដ្ឋ ។ ធម្មនុញ្ញសហប្រជាជាតិដែលចែងថា ឆន្ទៈប្រជាជនជាគ្រឹះនៃអំណាចសាធារណៈនោះ ពុំមាននៅក្នុងរបបនេះឡើយ ព្រោះអំណាចទាំងអស់ស្ថិតនៅលើមជ្ឈិមបក្សដែលមានគ្នាតែពីរបីនាក់ប៉ុណ្ណោះ ។ ចំណែកប្រទេសកម្ពុជាបច្ចុប្បន្ន ដែលក្នុងរដ្ឋធម្មនុញ្ញចែងថា កាន់របបប្រជាធិបតេយ្យសេរីពហុបក្សវិញ តើបានអនុវត្តដោយត្រឹមត្រូវតាមមាត្រានេះហើយឬនៅ ជាពិសេសការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្របង្កើតរដ្ឋាភិបាល ។ ការអនុវត្តន៍តាមធម្មនុញ្ញនៃអង្គការសហប្រជាជាតិ និងតាមរដ្ឋធម្មនុញ្ញខ្មែរបច្ចុប្បន្ន អាចឲ្យខ្មែរជៀសវាងសង្គ្រាមក្នុងស្រុកជាថ្មីទៀត ហើយអាចឲ្យខ្មែររួបរួមគ្នា ដោះស្រាយបញ្ហាជាតិ ឆ្ពោះទៅរកសន្តិភាពនិងវឌ្ឍនភាព និងទប់ទល់បរទេសដែលឈ្លានពានពីខាងក្រៅ ។៚